**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០១១......សហវ.......

# សារាចរ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី២ ជំហានទី២ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុវត្តតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងដំណាក់កាលទី១ មាន ៣ជំហាន នៅរដ្ឋបាលកណ្តាល សម្រាប់ក្រសួង ស្ថាប័ន ចំនួន២៣ និងមន្ទីរ អង្គភាពជំនាញចំនួន ១៨ នៅរាជធានី ខេត្ត និងក្នុងដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ រួចមកហើយ។

នៅក្នុងដំណាក់កាលទី២ ជំហានទី២ នេះ ប្រព័ន្ធ NRMIS នឹងដាក់ឱ្យអនុវត្តដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះ រដ្ឋបាលខណ្ឌទាំងអស់នៃរាជធានីភ្នំពេញ នឹងចាប់អនុវត្តពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ និងរដ្ឋបាលក្រុង ស្រុក នៅទូទាំងប្រទេស នឹងចាប់អនុវត្តពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តទៅ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តដាក់ឱ្យអនុវត្តប្រព័ន្ធ NRMIS ដល់រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត នៅក្នុងដំណាក់កាលនិងជំហានបន្តបន្ទាប់។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់លេខកូដបង់ចំណូលមិនមែនសារពើពន្ធដែលបានកំណត់ ដោយលម្អិតតាមចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត។ គ្រប់ចំណូលមិនមែនសារពើពន្ធទាំងអស់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលអាចប្រមូលនិងបង់ចូលថវិកាថ្នាក់ក្រោមជាតិ (ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ) បានលុះត្រាតែមានលេខកូដបង់ចំណូលដែលអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដែលស្នើដោយអគ្គនាយកដ្ឋានរដ្ឋបាល ឬ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ។ បញ្ជីលេខកូដចំណូលមិនមែនសារពើពន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ជាឧបសម្ព័ន្ធនៃសារាចរនេះ។

ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់វិក្កយបត្រដែលមានលេខកូដបង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចដាក់ចេញនូវសេចក្តីណែនាំអំពីនីតិវិធីនៃការប្រមូលនិងការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS និងបង់ចំណូលទៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ដូចខាងក្រោម÷

១. ការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS÷ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយពីទទួលបានចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ត្រូវកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS។

២. ពេលបង់ចំណូលទៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

-ចំពោះចំណូលពីសេវាសាធារណៈ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ចំនួន០២ច្បាប់ ដោយ ០១ច្បាប់រក្សាទុកជូនធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ និង ០១ច្បាប់ទៀត រក្សាទុកដោយរដ្ឋទេយ្យករចំណូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី ដើម្បីភ្ជាប់ជាមួយសាច់ប្រាក់ដែលត្រូវបង់ ឬ បង្វែរចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ

-ចំពោះចំណូលពីទ្រព្យសម្បត្តិរដ្ឋ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជនដើម្បីបង់ប្រាក់នៅធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ

-ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចអនុវត្តតាមនីតិវិធីនៃការបង់ចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋតាមយថាប្រភេទនៃចំណូលជាក់ស្តែង។

-ក្រោយពីបានបង់ប្រាក់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកត់ត្រាលេខយោងលើបណ្ណបង់ប្រាក់ (Bank Slip) ឬ ប្រកាសឥណពន្ធ (Debit Advice) ឬ បណ្ណផ្ទេរប្រាក់/ឥណទាន (Remittance Slip) ចូលក្នុងប្រព័ន្ធ NRMIS ដើម្បីបញ្ចប់ប្រតិបត្តិការ នៃវិក្កយបត្រ (ក្នុងករណីជាប្រាក់ដុល្លារអាមេរិក អត្រាប្តូរប្រាក់នឹងត្រូវកំណត់តាមធនាគារជាតិនៃកម្ពុជា)។

៣. ការបង្វែរចំណូលទៅថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ÷

-ប្រព័ន្ធ NRMIS នឹងធ្វើការបង្កើតសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយស្វ័យប្រវត្តិ បន្ទាប់ពីការធ្វើប្រតិបត្តិការបញ្ចប់វិក្កយបត្រ ដើម្បីបោះពុម្ពសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញពីប្រព័ន្ធ NRMIS។

-រដ្ឋទេយ្យករចំណូល ឬ មន្ត្រីទទួលបន្ទុកប្រមូលចំណូល របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗត្រូវពិនិត្យសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួចបញ្ជូនមករតនាគាររាជធានី ខេត្ត ជាមុន តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម Telegram បន្ទាប់មកត្រូវបញ្ជូនដីកាសម្រេចសលាកបត្របង់ចំណូលថវិកាក្រុង ស្រុក ខណ្ឌប្រចាំខែ និងតារាងលម្អិតដីកាសម្រេចសលាកបត្របង់ចំណូលថវិកាប្រចាំខែ ដែលមានការចុះហត្ថលេខា (ច្បាប់ដើម) មករតនាគាររាជធានី ខេត្តតាមក្រោយ។

៤. ប្រាក់ចំណូលពីកម្រៃសេវាសាធារណៈដែលរដ្ឋទេយ្យករចំណូល នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រមូលបាន ត្រូវបង់ទាំងអស់ទៅគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ បន្ទាប់ពីដកប្រាក់រង្វាន់រួច មុនចាប់ផ្តើមអនុវត្តប្រព័ន្ធ NRMIS។

៥. ការទូទាត់ប្រាក់រង្វាន់÷ ដើម្បីរៀបចំការទូទាត់ប្រាក់រង្វាន់ដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានដកកន្លងមក រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដើម្បីកត់ត្រា ដោយត្រូវជ្រើសរើសយកសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្វែរចូលថវិការួចហើយ តាមរយៈសាច់ប្រាក់ដែលបានបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ។ បន្ទាប់មកត្រូវបោះពុម្ពលិខិតស្នើសុំផ្សេងៗ និងរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រេចសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក និងផ្ញើមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីអនុវត្តនីតិវិធីបន្ត។ សម្រាប់ប្រតិបត្តិការចំណាយត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

៦. ប្រព័ន្ធ NRMIS នឹងត្រូវធ្វើសន្ទានកម្មជាមួយកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលរៀបចំដោយក្រសួងមហាផ្ទៃ ដើម្បីបង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ NRMIS ដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលប្រព័ន្ធ NRMIS ពុំទាន់អាចធ្វើសន្ទានកម្មជាមួយកម្មវិធីព័ត៌មានវិទ្យា

សម្រាប់គ្រប់គ្រងនិងផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបាន រដ្ឋទេយ្យករចំណូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ NRMIS ដោយផ្ទាល់ ឬ អាចធ្វើការបញ្ចូលប្រតិបត្តិការតាមរយៈទម្រង់ File Excel ដែលបានរៀបចំ និងផ្តល់ជូនដោយក្រុមការងារបច្ចេកទេសប្រព័ន្ធ NRMIS។

៧.រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល និងធនាគារពាណិជ្ជដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីឱ្យប្រើប្រាស់វិក្កយបត្រដែលមានលេខកូដបង់ចំណូលជាកំហិត។

ទទួលបានសារាចរនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ២កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានរតនាគារជាតិ
-អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
-រដ្ឋបាលរាជធានី ខេត្ត
-រដ្ឋបាលក្រុង ស្រុក ខណ្ឌ
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
-រតនាគាររាជធានី ខេត្ត
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ